រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៩

## សេចក្ដីសំរេចលេខ ៥៥ សសរ

## ស្ដីពីការបង្កើតក្រុមការងារ សហប្រតិបត្តិការជាមួយអ្នកជំនាញច្បាប់បរទេស ដើម្បីរៀបចំនីតិវិធី សំរាប់កាត់ទោសឧក្រិដ្ឋជនខ្មែរក្រហម

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- ផ្អែកលើការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** បង្កើតក្រុមការងារ សហប្រតិបត្តិការជាមួយអ្នកជំនាញច្បាប់បរទេសដើម្បីរៀបចំនីតិវិធីសំរាប់កាត់ទោសឧក្រិដ្ឋជនខ្មែរក្រហមដែលមានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| ១- ឯកឧត្តម សុខ អាន | ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | ជាប្រធាន |
| ២- ឯកឧត្តម អ៊ឹុក វិធុន | រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ជាអនុប្រធាន |
| ៣- ឯកឧត្តម ហេង វង្សប៊ុនឆាត | ឧត្តមទីប្រឹក្សារាជរដ្ឋាភិបាល | ជាអនុប្រធាន |
| ៤- ឯកឧត្តម ឱម យិនទៀង | ប្រធានគណៈកម្មការសិទ្ធិមនុស្សនៃរាជរដ្ឋាភិបាលកម្ពុជា | ជាអនុប្រធាន |
| ៥- លោកជំទាវ លី វ៉ូចឡេង | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ជាសមាជិក |
| ៦- ឯកឧត្តម ស៊ុយ នូ | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ជាសមាជិក |
| ៧- ឯកឧត្តម ចាន់ តានី | ទីប្រឹក្សាសម្ដេចនាយករដ្ឋមន្ត្រី | ជាសមាជិក |
| ៨- ឯកឧត្តម អន្ត វង្សវឌ្ឍនា | ទីប្រឹក្សាឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង | ជាសមាជិក |
| ៩- លោក ឡេង ប៉េងឡុង | ប្រធានក្រុមជំនាញក្រុមប្រឹក្សាអ្នកច្បាប់ | ជាសមាជិក |

**ប្រការ ២ :** ក្រុមការងារនេះ មានបេសកកម្ម

- សហការជាមួយអ្នកច្បាប់ ឬអ្នកឯកទេស ពិចារណាអំពីនីតិវិធី គិតគូរអំពីច្បាប់ និងបទដ្ឋានចាំបាច់ ដើម្បីបង្កើតតុលាការសំរាប់កាត់ទោសជនដែលជាប់ចោទ អំពីបទប្រល័យពូជសាសន៍ ។
- រៀបចំទីតាំង និងពិចារណាអំពីវិធានការដើម្បីរក្សាសណ្ដាប់ធ្នាប់ និងរបៀបរៀបរយ ពេលតុលាការធ្វើសវនាការ ។

- សហការជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីសំរេចកិច្ចការខាងលើនេះ ។

ប្រការ ៣ : ប្រធានក្រុមការងារ អាចកោះប្រជុំនិងអញ្ជើញតំណាងស្ថាប័នផ្សេងទៀត ប្រើប្រាស់លេខាធិការដ្ឋានមួយប្រើប្រាស់ទីតាំង ត្រា និងសំភារៈផ្សេងៗ របស់ទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីសំរេចបេសកកម្មនេះ ។

ប្រការ ៤ : ប្រធានក្រុមការងារ ត្រូវរាយការណ៍អំពីដំណើរការនៃក្រុមការងារ ឬបញ្ហាដែលត្រូវដោះស្រាយ ជូននាយករដ្ឋមន្ត្រី ព្រមទាំងធ្វើសេចក្តីរាយការណ៍បញ្ចប់ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋានដែលពាក់ព័ន្ធព្រមទាំងអស់លោកជំទាវ និងលោកឧត្តម ដែលមានរាយនាមក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# II- ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩

### ប្រកាសលេខ ៣៤៧ ពណ.នគក.ប្រក

### ស្តីពីការត្រួតពិនិត្យការចុះបញ្ជីពាណិជ្ជកម្ម

### តាមបណ្តាខេត្ត- ក្រុង

***

### រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់តាំង នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា